ផ្សារមូលបត្រកម្ពុជា

CSX

ក្រុមហ៊ុន ផ្សារមូលបត្រកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ថ្ងៃពុធ ១៣កើត ខែ បុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០២០

## សេចក្តីជូនដំណឹង

## ក្រុមហ៊ុន អេស៊ីលីដា ស៊ីឃ្យួរីធី ភីអិលស៊ី ជាប់ជ័យលាភីឈ្មួញជើងសារមូលបត្រឆ្នើម ប្រចាំត្រីមាសទី៤ ឆ្នាំ២០១៩

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក.) មានកិត្តិយសសូមជម្រាបជូនសាធារណជន មេត្តាជ្រាបថា ក្រុមហ៊ុន អេស៊ីលីដា ស៊ីឃ្យួរីធី ភីអិលស៊ី បានជាប់ជ័យលាភីឈ្មួញជើងសារមូលបត្រឆ្នើម សម្រាប់ត្រីមាសទី៤ ឆ្នាំ២០១៩ បន្ទាប់ពីត្រូវបានវាយតម្លៃយ៉ាងល្អិតល្អន់ក្នុងចំណោមឈ្មួញជើងសារមូលបត្រទាំង១០ក្រុមហ៊ុនដែលជាសមាជិករបស់ផ.ម.ក.។

កម្មវិធីឈ្មួញជើងសារមូលបត្រឆ្នើមនេះ ត្រូវបានបង្កើតឡើងក្នុងគោលបំណងទទួលស្គាល់នូវក្រុមហ៊ុនឈ្មួញជើងសារមូលបត្រឆ្នើម ដែលមានភាពឈានមុខគេប្រចាំត្រីមាសនីមួយៗពាក់ព័ន្ធនឹងការផ្តល់សេវាកម្មឈ្មួញជើងសារមូលបត្រសម្រាប់អតិថិជនរបស់ខ្លួន។

នៅក្នុងត្រីមាសទី៤ ឆ្នាំ២០១៩ ទំហំជួញដូរភាគហ៊ុនសរុបរបស់ក្រុមហ៊ុន អេស៊ីលីដា ស៊ីឃ្យួរីធី ភីអិលស៊ី មានចំនួន ៥,៦៧ ប៊ីលានរៀល។ ទន្ទឹមនឹងនេះ ចំនួនគណនីជួញដូរភាគហ៊ុនដែលបានបើកថ្មី មានចំនួន ១១២ គណនី ស្របពេលដែលចំនួនគណនីជួញដូរតាមប្រព័ន្ធជួញដូរចល័ត(MTS) ដែលបានបើកថ្មី មានចំនួន ៨២៦ គណនី និងទំហំជួញដូរតាមរយៈគណនី MTS មានចំនួន ៤,០៣ ប៊ីលានរៀល។

ផ្សារមូលបត្រកម្ពុជា
CSX
Cambodia Securities Exchange

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

លោកស្រី **គីម សុផានីតា** ប្រធាននាយកដ្ឋាន
នាយកដ្ឋានប្រតិបត្តិការទីផ្សារ
អ៊ីម៉ែល៖ sophanita.kim@csx.com.kh